# ស្មៅជើងបង្កង ឬស្មៅកន្ទុយក្រពើ (Alligator weed)

*Alternanthera philoxeroides*

## តើអ្វីទៅជាស្មៅជើងបង្កង?

ស្មៅជើងបង្កង គឺជាស្មៅមួយក្នុងចំណោមស្មៅដ៏សែនអាក្រក់បំផុតរបស់ពិភពលោក។ វាបណ្ដាលឱ្យខូចខាតទាំងនៅលើដី និងក្នុងទឹក។

រដ្ឋាភិបាលរដ្ឋវិចថូរៀ ទទួលខុសត្រូវក្នុងការកំចាត់ស្មៅជើងបង្កងទាំងអស់ ចេញពីរដ្ឋវិចថូរៀ។



**រូបថត៖ រូបថតជិតផ្កាស្មៅជើងបង្កង**

## ស្មៅជើងបង្កងមិនល្អទេសម្រាប់អ្នកបរិភោគ ឬដាំដុះនៅក្នុងសួនច្បាររបស់អ្នកទេ

ស្មៅជើងបង្កង តែងតែគេយល់ច្រឡំជាមួយនឹង Mukunuwenna (*Alternanthera sessilis*) ហើយត្រូវបានគេយកប្រើជាបន្លែស្លឹក។ ស្មៅជើងបង្កងគឺជារុក្ខជាតិមួយ ដែលអ្នកមិនចង់ដាំដុះនៅក្នុងសួនច្បាររបស់អ្នក ឬក៏បរិភោគ។

ស្មៅនេះអាចដុះរាលដាលយ៉ាងឆាប់រហ័ស និងប្រកួតប្រជែងជាមួយរុក្ខជាតិ ផ្លែឈើ និងបន្លែដទៃទៀត ដែលដាំដុះនៅក្នុងសួនច្បាររបស់អ្នក កាត់បន្ថយទិន្នផល ហើយប៉ះពាល់ដល់គុណភាពផលិតផលដាំដុះតាមផ្ទះ។

ស្មៅជើងបង្កងក៏អាចស្រូបយកលោហធាតុធ្ងន់ពីក្នុងដី ហើយមិនមានសុវត្ថិភាពក្នុងការបរិភោគឡើយ។

ស្មៅជើងបង្កង អាចដើរតួជាជម្រកសម្រាប់សត្វល្អិតចង្រៃ ដូចជាសត្វមូស ហើយអាចបណ្ដាលឱ្យពិបាកគ្រប់គ្រងនៅក្នុងសួនច្បាររបស់អ្នក។

## ស្មៅជើងបង្កងផលប៉ះពាល់ដល់បរិដ្ឋានរបស់យើង

ស្មៅជើងបង្កងអាចកាន់កាប់ផ្លូវទឹក សួនច្បារ វាលស្មៅ និងដីសម្រាប់ចិញ្ចឹមសត្វដែលស៊ីស្មៅជាអាហារ។

វាដុះរាលដាលយ៉ាងឆាប់រហ័ស និងងាយស្រួល ហើយពិបាកសម្លាប់ណាស់។

រុក្ខជាតិនេះមានគ្រោះថ្នាក់ដល់សត្វស្រុកអូស្ត្រាលី ដូចជាសត្វ playtypus ពីព្រោះវារារាំងផ្លូវទឹក និងកាត់បន្ថយចំណីអាហាររបស់សត្វនេះ។

វាបញ្ឈប់មនុស្សមិនឱ្យរីករាយនឹងសកម្មភាពនានា ដូចជាការស្ទូចត្រី ការជិះទូកកាយ៉ាក់ និងការជិះស្គីទឹក។

នៅតាមដងទន្លេ បឹង និងអូរ វាអាចបង្កើនថ្លៃចំណាយដល់កសិករ និងធ្វើឱ្យម្ហូបអាហាររបស់យើងថ្លៃជាងមុន។

## វិធីសម្គាល់ស្មៅជើងបង្កង



**រូបថត៖ ស្មៅជើងបង្កងបង្ហាញពីផ្កា និងស្លឹក**

ស្មៅជើងបង្កងអាចដុះលើដី និងក្នុងទឹក។ វាមានស្លឹកបៃតងភ្លឺថ្លា ដែលដុះជាគូតាមបណ្តោយដើម។

ដើមរបស់វាគឺប្រហោង។

ផ្កាដុះនៅលើទង ហើយមានពណ៌ស និងរូបរាងដូចបាល់។

## ជួយដោយការជូនដំណឹងមកយើងខ្ញុំ អំពីស្មៅជើងបង្កង

សូមជួយដល់ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលរដ្ឋវិចថូរៀ ដើម្បីកម្ចាត់ស្មៅជើងបង្កងទាំងអស់ចេញពីរដ្ឋវិចថូរៀ ដើម្បីការពារបរិស្ថាន និងឧស្សាហកម្មកសិកម្មដ៏មានតម្លៃរបស់យើង។

សូមប្រាប់ឱ្យយើងខ្ញុំដឹង ប្រសិនបើអ្នកមានស្មៅជើងបង្កងនៅក្នុងសួនច្បាររបស់អ្នក ឬប្រសិនបើអ្នកបានឃើញវាដុះនៅកន្លែងណាមួយ ដើម្បីឱ្យយើងខ្ញុំអាចយកវាចេញ និងបោះចោលវាឱ្យបានត្រឹមត្រូវ ដើម្បីជៀសវាងការដុះរាលដាល។

នេះគឺជាសេវាកម្មឥតគិតថ្លៃ ដែលផ្តល់ជូនដោយ Agriculture Victoria (កសិកម្ម  វិចថូរៀ)។

ទាក់ទងមក Agriculture Victoria (កសិកម្ម  វិចថូរៀ)ដោយ៖

- ទូរសព្ទមក មជ្ឈមណ្ឌលសេវាកម្មអតិថិជនរបស់យើងខ្ញុំ តាមលេខ 136 186 ឬ
- email weed.spotters@agriculture.vic.gov.au។

សូមកុំព្យាយាមគ្រប់គ្រង ឬបោះចោលស្មៅនេះដោយខ្លួនឯង ពីព្រោះនេះអាចបណ្តាលឱ្យវាដុះរាលដាល។

## AGRICULTURE VICTORIA (កសិកម្ម  វិចថូរៀ) សូមថ្លែងអំណរគុណចំពោះការជួយជ្រោមជ្រែងរបស់អ្នក ក្នុងការការពាររដ្ឋវិចថូរៀ ពីស្មៅឈ្លានពាននេះ។



**រូបថត៖ ស្មៅជេងបង្កងបង្ហាញពិផ្កា និងស្លិក**

---

### ភាពអាចចូលដំណើរការបាន

សម្រាប់ព័ត៌មានបន្ថែមអំពី Agriculture Victoria (កសិកម្ម វិចថូរៀ) សូមចូលទៅកាន់គេហទំព័រ www.agriculture.vic.gov.au ទូរសព្ទមកមជ្ឈមណ្ឌលសេវាកម្មអតិថិជន តាមលេខ 136 186។

---

AGRICULTURE VICTORIA